**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ១៣៣០២ ប្រ.ក

# ប្រកាស
# ស្តីពី
# តួនាទី និងភារកិច្ច
# របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ១៣៣០០ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ១៣៣០១ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- យោងតាមសំណើរបស់អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

## សម្រេច

**ប្រការ១.**

ប៉ុស្តិ៍នគរបាលរដ្ឋបាលស្ថិតនៅក្រោមឱវាទមេឃុំ ចៅសង្កាត់ និងស្ថិតនៅក្រោមការគ្រប់គ្រងបញ្ជាដឹកនាំជំនាញរបស់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថិរភាពសង្គមជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ។

**ប្រការ២.**

ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ចាត់វិធានការដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងមូលដ្ឋានឃុំ សង្កាត់
- ចាត់វិធានការ ការពារកន្លែងកើតហេតុ ប្រមូល ថែរក្សាវត្ថុតាង ធ្វើសេចក្តីរាយការណ៍ជូនអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងរាយការណ៍ផ្ទាល់ជូនមេឃុំ ចៅសង្កាត់
- គ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ ចំនួនគ្រួសារ ចំនួនមនុស្សស្នាក់នៅបណ្តោះអាសន្ន ស្នាក់នៅអចិន្ត្រៃយ៍ និងវត្តមានជនបរទេសក្នុងភូមិសាស្ត្រទទួលខុសត្រូវ
- ចាត់វិធានការគ្រប់គ្រងមុខសញ្ញាល្មើសច្បាប់នានា ក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- គ្រប់គ្រងការចុះបញ្ជីស្ថិតិអាវុធ គ្រឿងផ្ទុះ ជាតិងាយឆេះ ជាតិពុល មុខរបរដែលងាយប៉ះពាល់ដល់សន្តិសុខសង្គម និងយានជំនិះគ្រប់ប្រភេទតាមការកំណត់
- គ្រប់គ្រងបញ្ជីទិន្នន័យមានជាអាទិ៍ : ទីតាំងអង្គភាពកងកម្លាំងប្រដាប់អាវុធ ទីតាំងស្ថានទូត គ្រឹះស្ថានសិក្សា វត្តអារាម រមណីយដ្ឋាន ក្លឹបកំសាន្ត អង្គការជាតិ អន្តរជាតិនានា លំនៅដ្ឋានជនបរទេស ក្រុមហ៊ុនរោងចក្រ សហគ្រាស និងសហគមន៍
- ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ និងអនុវត្តគោលការណ៍ការងារនគរបាល និងសហគមន៍ សំដៅកៀរគរការចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- យាមប្រចាំការ ដើម្បីទទួលព័ត៌មាន និងអន្តរាគមន៍ការពារអាយុជីវិត សិទ្ធិសេរីភាព ទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ប្រតិបត្តិម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវបទវិន័យរបស់នគរបាលជាតិ សំដៅធ្វើឲ្យប្រជាពលរដ្ឋស្រឡាញ់ មានទំនុកចិត្ត គាំទ្រ និងរាយការណ៍ហេតុការណ៍ជូននគរបាល
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់ប៉ុស្តិ៍ជូនមេឃុំ ចៅសង្កាត់ និងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលមេឃុំ ចៅសង្កាត់ និងអធិការប្រគល់ឲ្យ ។

**ប្រការ៣.**

ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវបានបែងចែកប្រភេទចំនួន០៤ និងកំណត់ចំនួនក្របខ័ណ្ឌដូចខាងក្រោម :

ក- ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ១ មានក្របខ័ណ្ឌចំនួន (០៨-១២)

ខ- ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ២ មានក្របខ័ណ្ឌចំនួន (១៣-១៨)

គ- ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ៣ មានក្របខ័ណ្ឌចំនួន (១៩-២៥)

ឃ- ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ៤ មានក្របខ័ណ្ឌចំនួន (២៦-៣២) ។

**ប្រការ៤.**

ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដឹកនាំដោយនាយប៉ុស្តិ៍ចំនួន០១រូប និងមាននាយរងប៉ុស្តិ៍ចំនួន០១រូបជាជំនួយការ ។

**ប្រការ៥.**

អំពីភារកិច្ចរបស់នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ :

- បញ្ជាដឹកនាំកម្លាំង និងគ្រប់គ្រងមធ្យោបាយ យុទ្ធោបករណ៍របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- ដោះស្រាយការងារប្រចាំថ្ងៃ រៀបចំរបៀបរបប ផែនការ កម្មវិធី ទិសដៅការងាររបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល និងចាត់តាំងការប្រជុំណែនាំផ្សព្វផ្សាយ ដាក់ផែនការ ព្រមទាំងតាមដានត្រួតពិនិត្យការបំពេញភារកិច្ចរបស់មន្ត្រីក្រោមឱវាទតាមការកំណត់

- ទទួលសំណូមពរពីប្រជាពលរដ្ឋ និងផ្តល់សេវាដោះស្រាយដើម្បីសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងមូលដ្ឋាន
- រៀបចំវេនប្រចាំការអចិន្ត្រៃយ៍២៤ម៉ោង ដើម្បីទំនាក់ទំនងជួប និងទទួលព័ត៌មាន
- បូកសរុបវាយតម្លៃដាក់ពិន្ទុ មូលវិចារណ៍ លើកសំណើតែងតាំងឋានៈ ឋានន្តរសក្តិ សរសើរជូនរង្វាន់ដល់មន្ត្រីដែលមានស្នាដៃក្នុងការបំពេញភារកិច្ច និងត្រួតពិនិត្យអនុវត្តវិន័យចំពោះមន្ត្រីនគរបាលក្រោមឱវាទដែលអសកម្ម
- រៀបចំបញ្ជីសារពើភ័ណ្ឌ កាន់កាប់ ប្រើប្រាស់ និងថែរក្សាទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាព
- បំពេញភារកិច្ចផ្សេងៗទៀត ដែលមេឃុំ ចៅសង្កាត់ និងអធិការប្រគល់ឲ្យ ។

**ប្រការ៦..**

ទំនាក់ទំនងការងារ :

- រវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមេឃុំ ចៅសង្កាត់ជាទំនាក់ទំនងណែនាំអនុវត្តគោលការណ៍ ផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- រវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ ជាទំនាក់ទំនងបញ្ជាដឹកនាំការងារជំនាញ
- រវាងប៉ុស្តិ៍នគរបាលរដ្ឋបាល និងអង្គភាពពាក់ព័ន្ធ ជាទំនាក់ទំនងសហការដើម្បីសម្រេចភារកិច្ច ។

**ប្រការ៧..**

ប្រកាសលេខ៥៨៣ប្រ.ក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ ស្តីពីតួនាទី ភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងការកំណត់ទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ ។

**ប្រការ៨..**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងអធិការនៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល៖</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ៨*
*-ឯកសារ-កាលប្បវត្តិ*